# មង្គលសូត្រ

**ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។**

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អានាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

**អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ ។**

គ្រានោះឯង ទេវតា១អង្គ កាលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ញ៉ាំងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ បិត នៅក្នុងទីសមគួរ ។ លុះទេវតានោះ បិត នៅក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគដោយគាថា។

**ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ**
**អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។**

ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នារកសួស្តី បានគិតរកមង្គល ទាំងឡាយ សូមព្រះអង្គសម្តែងប្រាប់នូវមង្គលដ៏ឧត្តម ។

**អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា**

**បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ ។**

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ការមិនសេពគប់ពាលជន ទាំងឡាយ១ ការសេពគប់បណ្ឌិតជនទាំងឡាយ១ ការបូជាចំពោះ បុគ្គលដែលគួរបូជាទាំងឡាយ ១ នេះជាមង្គល ដ៏ឧត្តម ។

**បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា**

**អត្តសម្មាបណិធិ ច ឯតម្មង្គលមុត្តមំ ។**

ការនៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយ ក្នុងកាលមុន ១ ការដំកល់ខ្លួនប្រពៃ ១ នេះជាមង្គល ដ៏ឧត្តម ។

**ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ**

**សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ ។**

ភាវៈនៃបុគ្គលបានស្តាប់បានរៀនច្រើន ១ សិល្បៈគឺសេចក្តីឆ្លៀវឆ្លាត ក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សា ប្រពៃ ១ វាចាដែលបុគ្គលពោលល្អ ១ នេះជា មង្គល ដ៏ឧត្តម ។

**មាតាបិតុឧបដ្ឋានំ          បុត្តទារស្ស សង្គហោ**

**អនាកុលា ច កម្មន្តា          ឯតម្មង្គលមុត្តមំ ។**

ការបំរើមាតាបិតា ១ ការសង្គ្រោះដល់បុត្រ និងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ នេះជា មង្គល ដ៏ឧត្តម។

**ទានញ្ច ធម្មចរិយា ច          ញាតកានញ្ច សង្គហោ**

**អនវជ្ជានិ កម្មានិ          ឯតម្មង្គលមុត្តមំ ។**

ការបរិច្ចាគទាន ១ ការប្រព្រឹត្តធម៌ ១ សេចក្តីសង្គ្រោះញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ នេះជា មង្គល ដ៏ឧត្តម។

**អារតី វិរតី បាបា          មជ្ជបានា ច សញ្ញមោ**

**អប្បមាទោ ច ធម្មេសុ          ឯតម្មង្គលមុត្តមំ ។**

ការមិនត្រេកអរក្នុងបាប និងការវៀរចាកបាប ១ សេចក្តីសង្រួមចាកការផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ នេះជា មង្គល ដ៏ឧត្តម។

**គារវោ ច និវាតោ ច          សន្តុដ្ឋី ច កតញ្ញុតា**

**កាលេន ធម្មស្សវនំ          ឯតម្មង្គលមុត្តមំ ។**

សេចក្ដីគោរព ១ សេចក្ដីឱនលំទោន ១ សេចក្ដីត្រេកអរតាមមានតាមបាន ១ ភាពជាអ្នកដឹងនូវឧបការៈ ដែលអ្នកដទៃធ្វើហើយ ១ ការស្ដាប់នូវធម៌តាមកាល ១ នេះជាមង្គល ដ៏ឧត្ដម។

**ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ**

**កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។**

សេចក្ដីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ ការជួបប្រទះនូវសមណៈទាំងឡាយ ១ ការសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ នេះជាមង្គល ដ៏ឧត្ដម។

**តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចានទស្សនំ**

**និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។**

សេចក្ដីព្យាយាមដុតនូវបាបធម៌ ១ ការប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ ១ ការឃើញនូវអរិយសច្ចទាំងឡាយ ១ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ១ នេះជាមង្គល ដ៏ឧត្ដម។

**ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ**

**អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ ។**

ចិត្តនៃបុគ្គលណាដែលមានលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរម្ភើបញាប់ញ័រ ១ ការមិនមានសេចក្តីសោក ១ ធុលីគឺរាគៈទៅប្រាសហើយ ១ ចិត្តក្សេមក្សាន្ត ១ នេះជាមង្គល ដ៏ឧត្តម។

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា**

**សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ ។**

ទេវតា និងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តី ក្នុងទីទាំងពួង នេះជាមង្គល ដ៏ឧត្តម របស់ទេវតា និង មនុស្សទាំងឡាយនោះ ។

**ចប់មង្គលសូត្រ**

**សូមអនុមោទនា**!